THE EDUCATION STATE

SCHOOLS

# គំនិតផ្តួចផ្តើមការរៀនសូត្រជាមួយគ្រូបង្ហាត់បង្រៀន (TUTOR LEARNING INITIATIVE)៖ ព័ត៌មានសម្រាប់មាតាបិតា អ្នកថែទាំ និងអាណាព្យាបាល

ព័ត៌មាននេះគឺសម្រាប់មាតាបិតា អ្នកថែទាំ និងអាណាព្យាបាលស្តីអំពីគំនិតផ្តួចផ្តើមការរៀនសូត្រជាមួយគ្រូបង្ហាត់បង្រៀន (Tutor Learning Initiative) ដែលនឹងផ្គត់ផ្គង់សិស្សក្នុងការរៀនសូត្ររបស់ពួកគេនៅឆ្នាំ 2021។

ឆ្នាំសិក្សា 2020 គឺជាឆ្នាំមួយដែលខុសពីប្រក្រតី និងជាបញ្ហាប្រឈមសម្រាប់សហគមន៍សាលាទាំងអស់។

សិស្សវិចថូរៀជាច្រើនបានចំណាយពេលយ៉ាងច្រើនក្នុងត្រីមាសទី 2 និងទី 3 ក្នុងឆ្នាំនេះ ដើម្បីរៀនសូត្រពីចម្ងាយ ហើយសាលារៀនរដ្ឋវិចថូរៀ និងសហគមន៍របស់ពួកគេបានខិតខំយ៉ាងពិសេសក្នុងការផ្តល់ការបង្រៀន និងការរៀនសូត្រជាបន្តដល់សិស្សរបស់យើងក្នុងអំឡុងពេលនេះ។

ក្នុងអំឡុងត្រីមាសទី 4 សាលារៀននៅទូទាំងរដ្ឋវិចថូរៀ បានផ្តោតលើការគាំទ្រដល់សុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់សិស្ស បន្ថែមលើការជួយសិស្សឱ្យកែតម្រូវទៅការរៀនសូត្រនៅនឹងកន្លែង។ គ្រូក៏បានផ្តោតការយកចិត្តទុកដាក់លើការវាយតម្លៃការរៀនសូត្ររបស់សិស្ស ការដោះស្រាយគម្លាតនៃការរៀនសូត្ររបស់សិស្សម្នាក់ៗ និងការកំណត់អត្តសញ្ញាណសិស្សទាំងនោះដែលត្រូវការការគាំទ្របន្ថែមសម្រាប់ការរៀនសូត្ររបស់ពួកគេ ការប្រើការសង្កេត និងការវាយតម្លៃផ្អែកលើថ្នាក់រៀនផងដែរ។

យើងដឹងថាបទពិសោធន៍នៃការរៀនសូត្រពីចម្ងាយគឺខុសគ្នាសម្រាប់សិស្សគ្រប់រូប។ ខណៈពេលដែលមានសិស្សខ្លះចម្រើនលូតលាស់ល្អ ក៏មានសិស្សខ្លះប្រហែលជាមិនបានចូលរួមពេញលេញនៅក្នុងការរៀនសូត្រពីចម្ងាយទេ។ សម្រាប់សិស្សរបស់យើងភាគច្រើន ការបង្រៀនដែលមានគុណភាពខ្ពស់ទៀងទាត់នៅឆ្នាំ 2021 នឹងគ្រប់គ្រាន់ដើម្បីជួយពួកគេឱ្យឈានដល់កម្រិតនៃការរៀនសូត្រដែលរំពឹងទុក។ សិស្សមួយចំនួននឹងទទួលបានអត្ថប្រយោជន៍ ពីការគាំទ្រការរៀនសូត្រយ៉ាងល្អិតល្អន់បន្ថែមនៅឆ្នាំ 2021។

ដូចដែលអ្នកប្រហែលជាបានដឹងហើយ ក្នុងការឆ្លើយតបទៅនឹងបញ្ហានេះ រដ្ឋាភិបាលរដ្ឋវិចថូរៀកំពុងវិនិយោគទឹកប្រាក់ចំនួន 250 លានដុល្លារ នៅក្នុងគំនិតផ្តួចផ្តើមការរៀនសូត្រជាមួយគ្រូបង្ហាត់បង្រៀន (Tutor Learning Initiative) ដើម្បីជួយឱ្យសាលារៀននៅទូទាំងរដ្ឋវិចថូរៀ ទាក់ទិនគ្រូបង្រៀនចំនួន 4,100 នាក់ធ្វើជាគ្រូបង្ហាត់បង្រៀននៅឆ្នាំ 2021 ដើម្បីគាំទ្រដល់សិស្សដែលត្រូវការជំនួយបន្ថែមជាមួយនឹងការរៀនសូត្ររបស់ពួកគេ។ សាលារៀននឹងកំណត់ពីវិធីអនុវត្តគំនិតផ្តួចផ្តើមនេះឱ្យបានល្អបំផុតសម្រាប់សិស្សរបស់ពួកគេ ហើយនឹងធានាថាសិស្សនឹងទទួលបានការគាំទ្រនេះតាមរបៀបមួយដែលកាត់បន្ថយការរំខានដល់ការរៀនសូត្រ ឬសកម្មភាពរបស់សាលាផ្សេងទៀត។

ដោយការទាក់ទិនជាមួយគ្រូបង្រៀនបន្ថែម ដើម្បីគាំទ្រដល់កុមារជាមួយការរៀនសូត្រយ៉ាងល្អិតល្អន់ គ្រូប្រចាំថ្នាក់រៀននឹងមានសមត្ថភាពកាន់តែច្រើនដើម្បីធានាថាសមិទ្ធិផល ការចូលរួម និងសុខុមាលភាពរបស់សិស្សដទៃទៀតត្រូវបានបំពេញ ដើម្បីឱ្យសិស្សទាំងអស់ទទួលបានការគាំទ្រដែលពួកគេត្រូវការនៅឆ្នាំ 2021។

ព័ត៌មានបន្ថែមអំពីគំនិតផ្តួចផ្តើមការរៀនសូត្រជាមួយគ្រូបង្ហាត់បង្រៀន (Tutor Learning Initiative) និងរបៀបដែលវាត្រូវបានអនុវត្តសម្រាប់សិស្សដែលត្រូវការការគាំទ្រជាលក្ខណៈបុគ្គលនៅសាលារបស់យើង នឹងត្រូវបានចេញមុនពេលសិស្សចាប់ផ្តើមការបង្ហាត់បង្រៀននៅឆ្នាំ 2021។

ក្នុងអំឡុងត្រីមាសទី 4 សាលារៀននឹងធ្វើការជាមួយសិស្សដើម្បីស្វែងយល់ពីបទពិសោធន៍នៃការរៀនសូត្រពីចម្ងាយ និងការវិលត្រឡប់ទៅការរៀនសូត្រនៅសាលារៀនវិញរបស់ពួកគេ។

ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីការចូលរួមរបស់កូនអ្នកក្នុងការរៀនសូត្ររបស់ពួកគេ ខណៈពេលកំពុងរៀនសូត្រនៅផ្ទះ ឬបន្ទាប់ពីពួកគេត្រឡប់ទៅសាលារៀនវិញ សូមទាក់ទងមកសាលារៀនរបស់អ្នក។



VICTORIA State Government | Education and Training